កិច្ចការ១៤:១-២៨

# ជំពូក ១៤

***ខាងចុងនេះ*** *កិច្ចការព្រះវិញ្ញាណបរិសុទ្ធនៅស្រុកកាឡាទី*
*កិច្ចការព្រះវិញ្ញាណបរិសុទ្ធនៅក្រុងអ៊ីកូនាម*
*ហេតុការណ៍កើតឡើងនៅក្រុងលីស្ត្រា*

## កិច្ចការព្រះវិញ្ញាណបរិសុទ្ធនៅស្រុកកាឡាទី

ឥឡូវ យើងបានមកដល់គម្ពីរកិច្ចការជំពូក១៤ហើយ។ ជំពូកនេះ ពណ៌នាអំពីកិច្ចការដែលលោកសាវ័កប៉ុល និងលោកបាណាបាសបំពេញនៅក្នុងស្រុកកាឡាទី។ ស្រុកកាឡាទី គឺជាតំបន់ពិបាកផ្សាយដំណឹងល្អជាទីបំផុត។ នៅពេលដែលយើងសិក្សាសំបុត្ររបស់សាវ័កប៉ុលផ្ញើទៅកាន់ពួកជំនុំនៅទីក្រុងកាឡាទី ទើបឃើញកម្រិតនៃការលំបាកជាយ៉ាងណា។ ពួកជំនុំនៅទីក្រុងកាឡាទី ជាពួកជនដែលមានព្រលឹងវិញ្ញាណដូចទឹករលក ម្តងឡើង ម្តងចុះ ម្តងឆ្វេង ម្តងស្តាំ មិនដែលដើរបានត្រឹមត្រូវម្តងណាទេ។ ដូច្នេះហើយបានជាសាវ័កប៉ុលចុះទៅជាច្រើនលើកច្រើនសារ ដើម្បីកែតម្រង់ក្រុមជំនុំនៅស្រុកកាឡាទី។

តើអ្នកស្រុកកាឡាទីជាអ្នកស្រុកណា? ពួកអ្នកស្រុកនេះ មានដើមកំណើតមកពីពូជសាសន៍ហ្គោល គឺជាពូជសាសន៍ដែលសព្វថ្ងៃនេះ ភាគច្រើនជាអ្នកស្រុកប្រទេសបារាំង។ នៅសតវត្សរ៍ទីបួន សាសន៍ហ្គោលនាំគ្នាងើបឡើងបះបោលទាស់ជាមួយនឹងរាជការរ៉ូម រហូតដល់វាយឈ្នះទាហានរ៉ូម នៅក្នុងតំបន់នោះផង។ នៅឆ្នាំ២៨០មុនគ្រីស្ទសករាជ សាសន៍ហ្គោលបានចូលឈ្លានពានសាសន៍ក្រេក រួចហើយចាប់យកទីក្រុងដែលហ្វីមកធ្វើជាស្រុកចំណុះរបស់ខ្លួន។ ក្រោយមកទៀត ស្តេចមួយអង្គនាមនីកូមីត គឺជាក្សត្ររបស់ស្រុកប៊ីធូនា បានហៅសាសន៍អោយទៅជយយំរំលត់ភ្លើងសង្គ្រាមស៊ីវិលនៅក្នុងប្រទេសលោក។ ដោយសារមូលហេតុនោះហើយ បានជាសាសន៍ហ្គោលអាចចូលទៅតាំងទីលំនៅនៅក្នុងអាស៊ីខាងលិច រៀងរហូតមក។ នៅឆ្នាំ១៨៩មុនគ្រីស្ទសករាជ រាជការរ៉ូមបានបង្ក្រាបសាសន៍ហ្គោលអោយនៅក្រោមអំណាចរបស់ខ្លួនវិញ ដោយបង្ខំអោយសាសន៍នេះរស់នៅក្នុងខេត្តមួយដាច់ដោយឡែក។ ព្រំដែនរបស់សាសន៍ហ្គោលម្តងធំម្តងតូច តែសាសន៍នេះអាចរក្សាប្រពៃណីទំនៀមទម្លាប់និងភាសារបស់ខ្លួន បានយ៉ាងជាប់លាប់អស់រយៈពេលជាច្រើនរយឆ្នាំ។ ក្រុមជំនុំដែលសាវ័កប៉ុលបង្កើតក្នុងពេលដែលលោកធ្វើ ដំណើរបេសកកម្មលើកទីមួយជាក្រុមជំនុំដែលពីដើមជាសាសន៍ហ្គោលបានតាំងទីលំនៅ។ ដូច្នេះ បានជាសាវ័កប៉ុលហៅពួកជំនុំនោះថាជាពួកជំនុំទីក្រុងនោះថាជាក្រុងកាឡាទី។

ខ្ញុំសូមជម្រាបបន្តិចពីភូមិសាស្ត្រ នៃការធ្វើដំណើរបេសកកម្មលើកទីមួយរបស់សាវ័កប៉ុល។ សាវ័កប៉ុលហើយនិងលោកបាណាបាសធ្វើដំណើរ ដំបូងឡើយលោក

ចេញពីទីក្រុងអាន់ទីយ៉ូក ក្នុងខេត្តស៊ីរី ដើរកាត់កោះគីប្រុស មកដល់ដែរប៉ាមផុស។ លោកចុះសំពៅឆ្លងនៅទីនោះទៅពើកា រួចហើយចេញពីពើកាទៅក្រុងអាន់ទីយ៉ូក នៅក្នុងខេត្តពិស៊ីឌា។ ចេញពីទីក្រុងអាន់ទីយ៉ូក លោកធ្វើដំណើរទៅទីក្រុងអ៊ីកូនាម លីស្ត្រានិងឌើបេ។ មកដល់ឌើបេ លោកត្រឡប់ទៅកាន់លីស្ត្រា អ៊ីកូនាម រួចទៅអាន់ទីយ៉ូក បានធ្វើដំណើរចុះមកអាតាលីយ៉ា ហើយចុះសំពៅទីនោះ ធ្វើដំណើរត្រឡប់មកទីក្រុងអាន់ទីយ៉ូកខេត្តស៊ីរីវិញ ដ្បិតជាកន្លែងដែលពួកជំនុំបញ្ជូនលោកអោយចេញទៅបម្រើព្រះអង្គ។

ពួកសាសន៍កាឡាទីជាសាសន៍ដែលមានសម្បុរសណ្ដែកបាយ ព្រោះជាជាតិសាសន៍អាស៊ី។ តើមនុស្សដទៃទៀត គេនិយាយពីចរឹតលក្ខណៈរបស់សាសន៍ហ្គោលថាយ៉ាងម៉េច? មហារាជសេសារដែលគ្រប់គ្រងចក្រភពរ៉ូមទាំងមូល បានសម្ដែងព្រះទ័យរបស់ទ្រង់អំពីដំណើរសាសន៍ហ្គោលនេះថា "សាសន៍ហ្គោល គឺជាសាសន៍ដែលរអិលដូចជាអន្ទង់ ប៉ិនធ្វើពុតមាយា ព្រមទាំងមិនគួរអោយទុកចិត្តសោះឡើយ"។ ចំណែកឯអ្នកប្រាជ្ញមួយរូបទៀត ដែលរស់នៅក្នុងសម័យស្ដេចសេសារដែរ បាននិយាយថា "សាសន៍ហ្គូល គឺជាសាសន៍ដែលចូលចិត្តនិយាយមិនបណ្ដាក់មាត់ តែលាក់កំនួចឆ្លាតវាងវៃ ពូកែធ្វើអាកប្បកិរិយាខាងក្រៅអោយទុកចិត្ត ប៉ុន្តែជាមនុស្សមិនអាចយកជាការបាន។ សាសន៍ហ្គោលចូលចិត្តធ្វើអ្វីដែលគ្មានប្រយោជន៍ច្រើនណាស់"។ សាវ័កប៉ុលបានសម្ដែងអំពីកិរិយាមាយាទរបស់សាសន៍ហ្គូល នៅក្នុងសំបុត្ររបស់លោកដែលសរសេរទៅទីក្រុងកាឡាទី។ អត្តចរឹកពួកពាររបស់សាសន៍ហ្គោលនៅក្នុងស្រុកកាឡាទី

ចូលចិត្តសម្រេចតាមបក្សតាមពួកខ្លាំងណាស់។ យើងគ្រប់គ្នាក៏មិនខុសអំពីមនុស្សដែលនៅក្នុងស្រុកកាឡាទីប៉ុន្មានទេ ពីព្រោះថ្ងៃនេះយើងតាមអ្នកនេះ ថ្ងៃស្អែកបើគេនិយាយពូកែជាងអ្នកម្សិលមិញ ក៏តាមគេទៅ។ បើអ្នកនយោបាយណាចុះទៅស្រុកកាឡាទី ច្បាស់ជាឈឺក្បាលជាមិនខាន ពីព្រោះថ្ងៃនេះគេថា អ្នកនេះល្អ ថ្ងៃស្អែកទៀតថាអ្នកនោះល្អ។ បើជ្រុលនិយាយរបូតមាត់ដោយប្រការណាមួយ អ្នកមកក្រោយទៀតនឹងប្រមូលអោយគេទៅបោះឆ្នោតអោយអ្នកនោះទាំងអស់ជាមិនខាន។ តើអ្នកស្រុកកាឡាទីដែលជាមនុស្សក្រឡិចក្រឡុច ខុសអំពីលក្ខណៈរបស់យើងជាមនុស្សមានបាបដែរឬ? យើងមិនសូវខុសអំពីអ្នកស្រុកកាឡាទីប៉ុន្មានទេ។

គម្ពីរកិច្ចការជំពូក១៤ បន្សល់ទុកនូវសេចក្តីដែលយើងទាំងអស់គ្នាត្រូវយកមករៀនសូត្រ។ អ្នកប្រាជ្ញគម្ពីរមួយរូប ជាបិតានៃចលនាប្រូតេស្តង់ គឺលោកម៉ាទិនលូធ័រយកសំបុត្ររបស់សាវ័កប៉ុលដែលសរសេរទៅទីក្រុងកាឡាទី មកធ្វើជាឯកសារសម្រាប់ធ្វើការបដិវត្តន៍សាសនា ពីព្រោះសាវ័កប៉ុលសរសេរទៅកាន់មនុស្សដែលមានលក្ខណៈជាអ្នកកាន់សាសនា ប៉ុន្តែមិនអនុវត្តតាមជំនឿដែលខ្លួនជឿនោះទេ។

# កិច្ចការព្រះវិញ្ញាណបរិសុទ្ធនៅក្រុងអ៊ីកូនាម

**កាលនៅក្រុងអ៊ីកូនាម ក៏នាំគ្នាចូលទៅក្នុងសាលាប្រជុំរបស់សាសន៍យូដា បានអធិប្បាយនាំឱ្យទាំងពួកសាសន៍យូដា នឹងសាសន៍ក្រេកយ៉ាងសន្ធឹកបានជឿ (កិច្ចការ១៤:១)។**

ដូចខ្ញុំបានជម្រាបរួចមកហើយថា សាវ័កប៉ុលនិងលោកបាណាបាសបានចេញទៅបំពេញបេសកកម្មលើកទីមួយ ដោយមានក្រុមជំនុំនៅទីក្រុងអាន់ទីយ៉ូក ខេត្តស៊ីរី ចាត់បញ្ជូនលោកទៅ។ លោកទាំងពីរនិងក្រុមរបស់លោកបានធ្វើដំណើរចុះសំពៅនៅក្បែរក្រុងអាន់ទីយ៉ូក រួចហើយឡើងនៅផែសាលាមីន។ លោកធ្វើដំណើរកាត់កោះគីប្រុសទាំងមូល រហូតទៅដល់កំពង់ផែមួយទៀតឈ្មោះប៉ាមផុស។ ពីប៉ាមផុស លោកធ្វើដំណើរទៅក្រុងពើកាក្នុងខេត្តប៉ាមភីលា។ ពីទីក្រុងពើកាលោកធ្វើដំណើរចូលទៅទ្វីបអាស៊ីខាងលិច ដែលមានក្រុងអាន់ទីយ៉ូក ក្រុងអ៊ីកូនាម លីស្ត្រា និងឌើបេ។ ក្រុងទាំងអម្បាលមាណនេះ គឺជាទីប្រជុំជនរបស់ស្រុកកាឡាទី។ ដូច្នេះ ក្នុងពេលធ្វើដំណើរទៅបំពេញបេសកកម្មលើកទីមួយ លោកបានចូលទៅក្នុងតំបន់ដែលជាបេះដូងនៃទឹកដីអាស៊ីភាគខាងលិច។

**២ប៉ុន្តែ ឯពួកសាសន៍យូដាដែលមិនព្រមជឿ គេញុះញង់ ហើយ**
**ចាក់រុកពួកសាសន៍ដទៃ ឱ្យគេទាស់នឹងពួកជំនុំវិញ ៣ចំណែកប៉ុល**
**នឹងបាណាបាស ក៏នៅទីនោះជាយូរថ្ងៃ គេអធិប្បាយយ៉ាងក្លៀវក្លា**
**ដោយនូវព្រះអម្ចាស់ ហើយទ្រង់ក៏ធ្វើបន្ទាល់ អំពីព្រះបន្ទូលនៃព្រះ**
**គុណទ្រង់ ដោយទ្រង់ប្រោសប្រទានឱ្យមានទីសំគាល់ នឹងការ**
**អស្ចារ្យកើតមកដោយសារដៃអ្នកទាំង២នោះ ៤ឯមនុស្សទាំង**
**ឡាយនៅទីក្រុងនោះ គេបែកបាក់គ្នា អ្នកខ្លះកាន់ខាងសាសន៍**
**យូដា ខ្លះខាងពួកសាវក (កិច្ចការ១៤:២-៤)។**

សាវ័កប៉ុលហើយនិងលោកបាណាបាស បានធ្វើអោយអ្នកស្រុកនៅក្នុងទីក្រុងទាំងមូលរង្កៀលចិត្តគ្នា។ លោកទាំងពីររូបសុទ្ធតែជាសាសន៍យូដា។ ដូច្នេះ រាល់ពេលណាដែលលោកទៅដល់ទីកន្លែងថ្មី លោកតែងតែទៅជួបជុំ សាសន៍យូដានៅក្នុងសាលាប្រជុំ។ លុះសាសន៍យូដាមិនព្រមទទួលដំណឹងល្អ លោកក៏ផ្សាយដំណឹងល្អដល់សាសន៍ដទៃតែម្តងទៅ។

**៥តែកាលពួកសាសន៍ដទៃ នឹងពួកសាសន៍យូដា ព្រមទាំងពួក**
**នាម៉ឺនរបស់គេ បានលើកព្រួតគ្នានឹងទៅធ្វើទុក្ខ ហើយ**
**ចោលនឹងថ្ម ៦នោះអ្នកទាំង២បានដឹង ហើយក៏រត់ទៅឯទីក្រុងនៅ**

**ស្រុកលូកៅនាវិញ គឺលីស្រ្តា នឹងឌើបេ ហើយនឹងស្រុកនៅជុំវិញ**
**[៧]ក៏ប្រកាសប្រាប់ដំណឹងល្អនៅកន្លែងទាំងនោះ (កិច្ចការ១៤: ៥-**
**៧)។**

នៅទីក្រុងអ៊ីកូនាម អ្នកស្រុកបដិសេធមិនស្តាប់ដំណឹងល្អតាមរយៈលោកឡើយ។ អ្នកស្រុកនៅក្នុងក្រុងអ៊ីកូនាម បានគម្រាមកំហែង ព្រមទាំងវាយលោករហូតដល់លោករត់ភៀសខ្លួនពីទីនោះ ទៅឯទីក្រុងលីស្រ្តា និងឌើបេវិញ។ ប៉ុន្តែ ទោះយ៉ាងនោះក៏ដោយ សាវ័កប៉ុលនិងលោកបាណាបាស បានត្រឡប់មកទីក្រុងនោះម្តងទៀត ពីព្រោះមានអ្នកជឿខ្លះនៅទីនោះដែរ។

## ហេតុការណ៍កើតឡើងនៅក្រុងលីស្រ្តា

**[៨]រីឯនៅក្រុងលីស្រ្តា មានមនុស្សម្នាក់មានជើងពិការ គាត់អង្គុយ**
**នៅដោយខ្វិន តាំងតែពីផ្ទៃម្តាយមក មិនដែលដើរសោះឡើយ**
**[៩]អ្នកនោះបានឮប៉ុលអធិប្បាយ ហើយប៉ុលក៏សំឡឹងមើលទៅគាត់**
**ឃើញថា គាត់មានសេចក្តីជំនឿល្មម ដើម្បីឱ្យបានជា [១០]នោះក៏**
**បន្លឺជាសំឡេងខ្លាំងថា ចូរក្រោកឈរឱ្យត្រង់ឡើង រួចអ្នកនោះក៏**
**ស្ទុះឡើងដើរ (កិច្ចការ១៤:៨-១០)។**

ដូចយើងឃើញស្រាប់ហើយថា សាវ័កប៉ុលនិងលោកបាណាបាសមាន អំណោយទានដូចព្រះជាម្ចាស់ប្រទានមកដល់ពួកសាវ័កដទៃៗទៀតដែរ ពោលគឺលោក អាចធ្វើទីសម្គាល់បាន។ នៅពេលដែលលោកទាំងពីរចូលទៅដល់តំបន់ដែលជាបេះដូង នៃអាស៊ីចុងខាងលិច លោកមិនមានព្រះគម្ពីរសញ្ញាថ្មីយកទៅជាមួយទេ ពីព្រោះ មិនទាន់មាននៅឡើយ។ បើគ្មានគម្ពីរយ៉ាងដូច្នេះ តើធ្វើដូចម្តេចអោយគេដឹងថា លោក ជាមនុស្សដែលព្រះជាម្ចាស់ចាត់បញ្ជូនអោយទៅនាំដំណឹងល្អប្រាប់ដល់គេ? ទីសម្គាល់ ដែលអាចធ្វើការអស្ចារ្យ គឺជាសញ្ញាដែលបញ្ជាក់ថា លោកជាមនុស្សដែលព្រះជាម្ចាស់ ចាត់បញ្ជូនអោយនាំដំណឹងល្អទៅដល់ពួកបណ្តាជន។ ចុះសព្វថ្ងៃវិញ តើក្រុមជំនុំរបស់ ព្រះអង្គដឹងថា មនុស្សម្នាក់មកពីព្រះ ដើម្បីមកប្រាប់ដំណឹងល្អដល់មនុស្សលោកដោយ សារអ្វី? សព្វថ្ងៃយើងមិនចាំបាច់ត្រូវការទីសម្គាល់ទៀតទេ ពីព្រោះយើងមានព្រះគម្ពីរ ទាំងមូលហើយ គឺព្រះគម្ពីរសញ្ញាចាស់ និងព្រះគម្ពីរសញ្ញាថ្មីហើយ។ យើងមិនចាំបាច់ ត្រូវការទីសម្គាល់ទៀតទេ បើយើងកាន់តាមគោលទ្ធិរបស់ពួកសាវ័កនៅក្នុងព្រះគម្ពីរ ហើយ យើងពិតជាមនុស្សដែលព្រះជាម្ចាស់បញ្ជូនទៅអោយផ្សាយដំណឹងល្អដល់អ្នក ដទៃជាប្រាកដ។ តើចំណុចណាមួយ ដែលរាប់ថាជាការកាន់តាមគោលទ្ធិរបស់ពួក សាវ័ក?

ដើម្បីឆ្លើយនឹងសំណួរខាងលើ ខ្ញុំឮលោកគ្រូអធិប្បាយម្នាក់ គាត់ អោយឧទាហរណ៍ពីរឿងនោះ។ លោកបានទៅវាយសីជាមួយនឹងបុរសម្នាក់ ដែលជាអ្នក មាន។ អ្នកមាននោះមិនមែនជាអ្នកជឿដល់ព្រះអង្គទេ។ គ្រូអធិប្បាយនោះព្យាយាម

ផ្សាយដំណឹងល្អប្រាប់គាត់។ អ្នកមានម្នាក់នោះ ស្គាល់គ្រូអធិប្បាយនោះច្បាស់ណាស់ ពីព្រោះសម្ដីសំដៅនឹងកិរិយាមារយាទរបស់លោក សម្ដែងអំពីចេស្ដារបស់ព្រះអម្ចាស់យេស៊ូវ ដែលសម្ដែងនៅក្នុងព្រះគម្ពីរបរិសុទ្ធ។ លុះលោកគ្រូនោះពន្យល់ដំណឹងល្អហើយ អ្នកមានតបថា "ខ្ញុំជឿថា ព្រះយេស៊ូវបានសុគត ព្រមទាំងបានរស់ឡើងវិញមែន។ បើខ្ញុំជឿលើព្រះយេស៊ូវខ្ញុំនឹងបានរួចពីបាបជាប្រាកដ"។ គ្រូគង្វាលសួរថា "ហេតុអ្វីបានជាលោកមិនព្រមជឿ?" អ្នកមានម្នាក់នោះ បានរៀបរាប់អំពីឈ្មោះរបស់គ្រីស្ទបរិស័ទជាច្រើនរូប បានធ្វើអាក្រក់ បានភូតភរ បាននិយាយអួតអាង ព្រមទាំងរស់ក្នុងជីវិតដែលមិនបរិសុទ្ធថ្វាយព្រះ។ គ្រូអធិប្បាយនោះក៏ឆ្លើយត្រឡប់មកវិញថា "សូមកុំអោយមើលមនុស្សខ្លាំងពេក។ នៅសម័យដើម មនុស្សនាំគ្នាសំឡឹងមើលការអស្ចារ្យដែលពួកសាវ័កបានធ្វើ។ គេមិនបានមើលពួកសាវ័កទាំងនោះទេ។ ដូច្នេះ ដើម្បីជឿដល់ព្រះអម្ចាស់យេស៊ូវ ត្រូវដកភ្នែកអំពីចំណុចខ្សោយរបស់គ្រីស្ទបរិស័ទទៅ។ ត្រូវអានព្រះបន្ទូលរបស់ព្រះដែលព្រះអង្គសម្ដែងអំពីអង្គព្រះយេស៊ូវគ្រីស្ទវិញ។ លោកត្រូវអានព្រះបន្ទូលរបស់ព្រះ ដើម្បីអោយដឹងថា តើព្រះជាម្ចាស់មានបន្ទូលមកកាន់លោករៀងរាល់ថ្ងៃ។ បើលោកមានទំនាក់ទំនងផ្ទាល់ខ្លួនជាមួយនឹងព្រះអម្ចាស់យេស៊ូវហើយ លោកមិនសូវជាចង់និយាយពីកំហុសគេប៉ុន្មានទេ"។ អ្នកមាននោះឆ្លើយត្រឡប់មកវិញថា "ខ្ញុំជឿព្រះមិនកើតទេ ដ្បិតខ្ញុំមិនអាចមើលឃើញព្រះ ដោយមិនឃើញមនុស្សឡើយ"។ មិនតែប៉ុណ្ណោះ អ្នកមានម្នាក់នោះបានចំអន់ដល់គ្រូអធិប្បាយថា លោកគ្រូអធិប្បាយអោយផ្លូវលោកជ្រើសរើសចង្អៀតពេក។ អ្នកមានម្នាក់នោះ មិនព្រមទទួលជឿដល់

ព្រះអម្ចាស់យេស៊ូវទេ ដោយសារលោកឃើញជីវិតគ្រីស្ទបរិស័ទខ្លះ ធ្វើបន្ទាល់មិនល្អ ចំពោះអ្នកមិនជឿ។ ប៉ុន្តែទោះជាយ៉ាងនោះក៏ដោយ ខ្ញុំចង់ជម្រាបដល់លោកអ្នក បងប្អូនថា គ្រីស្ទបរិស័ទមិនមែនជាមនុស្សដែលឥតខ្ចោះនោះទេ។ គ្រីស្ទបរិស័ទគ្រាន់តែ ជាមនុស្សដែលព្រះគ្រីស្ទយេស៊ូវមិនយកទោសកំហុសរបស់គេតែប៉ុណ្ណោះ។ គ្រីស្ទបរិស័ទក៏ជាមនុស្សដែលមានជើងទ័លដៃទ័លដូចជាអ្នកមិនជឿដែរ។

ពួកមនុស្សនៅទីក្រុងលីស្ត្រា នាំគ្នាសំឡឹងមើលលោកប៉ុលនិងលោកបាណាបាស។

**កាលហ្វូងមនុស្សបានឃើញការដែលប៉ុលធ្វើ នោះគេបន្លឺឡើងជាភាសាលូកៅនាថា ពួកព្រះបានកាឡានិម្មិតជាមនុស្ស ចុះមកឯយើងហើយ (កិច្ចការ១៤:១១)។**

មនុស្សខ្វិនមួយរូបនេះមានជំនឿយ៉ាងខ្លាំង ដែលបណ្តាលអោយសាវ័កប៉ុល ប្រាប់អោយគាត់ក្រោកឡើង។ នៅពេលដែលសាវ័កប៉ុលបង្គាប់គាត់អោយងើបឡើង គាត់ក៏ងើបឈរ រួចហើយហក់ ព្រមទាំងដើរសរសើរដំកើងដល់ព្រះជាម្ចាស់។ អ្នកស្រុក តំបន់នោះ សុទ្ធតែជាអ្នកដែលមិនស្គាល់ព្រះអម្ចាស់យេស៊ូវទេ។ នៅពេលដែលសាវ័ក ប៉ុលបានប្រោះជម្ងឺដល់អ្នកខ្វិនម្នាក់នេះ អ្នកស្រុកនៅក្រុងលីស្ត្រា នាំគ្នាប្រកាសយ៉ាង អឺងកងថា សាវ័កប៉ុលនិងលោកបាណាបាសសុទ្ធតែជាព្រះ។ គេទាំងអស់គ្នាសំឡឹងមើល

មកសាវ័លប៉ុលនិងលោកបាណាបាស រួចហើយក៏មានចិត្តគិតថា លោកជាមនុស្សមក ពីពិភពផ្សេង។

**[១២] គេក៏ហៅបាណាបាសជាព្រះសេយូស ហើយប៉ុល ជាព្រះ ហើមេស ពីព្រោះគាត់ជាមេសំដែង [១៣] ហើយសង្ឃរបស់ព្រះ សេយូស ដែលនៅមុខក្រុងគេ ក៏នាំយកគោឈ្មោល ហើយនឹង ភួងទៅដល់ខ្លោងទ្វារក្រុង ចង់ថ្វាយយញ្ញបូជាជាមួយនឹងបណ្តា មនុស្ស (កិច្ចការ១៤:១២-១៣)។**

លោកប៉ុល គឺជាមេក្នុងចំណោមអ្នកនិយាយទាំងអស់។ អ្នកស្រុកលីស្ត្រាលើក លោកឡើងថាជាព្រះ។ គេនាំយកកម្រងផ្កា ព្រមទាំងយញ្ញបូជាមកដើម្បីថ្វាយបង្គំដល់ សាវ័កប៉ុល និងលោកបាណាបាស។ អ្នកស្រុកនេះ ពិតជាមានវិញ្ញាណវៀចវេរមែន។ តើសព្វថ្ងៃមនុស្សលោកមិនមែនមានវិញ្ញាណវៀចវេរ ដូចអ្នកស្រុកកាឡាទីទេឬ? មនុស្ស លោកសព្វថ្ងៃនេះ មានលក្ខណៈមិនខុសអំពីអ្នកស្រុកកាឡាទីប៉ុន្មានទេ ដ្បិតម្សិលមិញ ដោយសារអ្នកនយោបាយចែកអង្ករ ចែកសារុង ក៏អោយចិត្តទៅអ្នកនោះ។ ថ្ងៃនេះ ឃើញអ្នកទាត់បាល់ល្អ ក៏អោយចិត្តទៅគេទៅ។ ក្រោយមកឃើញមនុស្សម្នាក់ចេះ ច្រៀងល្អ ក៏អោយចិត្តទៅគេ។ ចុងក្រោយបង្អស់ មានអ្នកនយោបាយមួយបក្សមកទៀត និយាយពិរោះដោយសន្យាថាយ៉ាងនេះ ឬយ៉ាងនោះ ក៏អោយចិត្តទៅគេទៀតទៅ។

សណ្ឋានរបស់មនុស្សជាតិ មិនដែលផ្លាស់ប្រែទេ។ ចំណែកវាសនារបស់គ្រូអធិប្បាយក៏ដូចគ្នាដែរ។ នៅថ្ងៃបរិសុទ្ធមួយនោះ គេនាំគ្នាសរសើរដល់គាត់ថា ព្រះបន្ទូលដែលលោកគ្រូអធិប្បាយពិរោះខ្លាំងណាស់។ ថ្ងៃក្រោយមកទៀត ក្រុមមនុស្សដដែលនោះបាននាំគ្នារកកំហុសគ្រូគង្វាល ព្រមទាំងចង់យកលោកទៅឆ្កាងថែមទៀតផង។

> **[១៤]កាលបាណាបាស នឹងប៉ុល ជាសាវកបានដឹង នោះក៏ហែកអាវ
> ខ្លួន រត់ចូលទៅកណ្ដាលហ្វូងមនុស្សស្រែកឡើងថា [១៥]អ្នករាល់គ្នា
> អើយ ហេតុអ្វីបានជាធ្វើ ដូច្នេះ យើងខ្ញុំជាមនុស្សវិស័យដូច
> ជាអ្នករាល់គ្នាដែរ មួយទៀត យើងក៏ប្រកាសប្រាប់ដំណឹងល្អដល់
> អ្នករាល់គ្នា ឱ្យបានបែរចេញពីអស់ទាំងការ ដែលឥតប្រយោជន៍
> យ៉ាងនេះ ទៅឯព្រះដ៏មានព្រះជន្មរស់វិញ ដែលទ្រង់បង្កើតផ្ទៃ
> មេឃ ផែនដី សមុទ្រ នឹងរបស់ទាំងអស់ដែលនៅស្ថានទាំងនោះ
> ផង [១៦]ក្នុងកាលជំនាន់មនុស្សពីបុរាណ នោះទ្រង់បានអនុញ្ញាតឱ្យ
> គ្រប់ទាំងសាសន៍ ដើរតាមផ្លូវរបស់គេរៀងខ្លួន (កិច្ចការ១៤:
> ១៤-១៦)។**

សាវ័កប៉ុលនិងលោកបាណាបាស មិនមែនគ្រាន់តែភ្ញាក់ផ្អើលចំពោះពួកមនុស្សនៅទីក្រុងលីស្ត្រាចង់មកថ្វាយបង្គំលោកតែប៉ុណ្ណោះទេ គឺលោកថែមទាំងចង់គាំង

បេះដូងថែមទៀតផង។ លោករត់ចូលទៅក្នុងចំណោមពួកអ្នកស្រុក ដើរប្រកាសប្រាប់គេថា "អ្នករាល់គ្នាអើយ ហេតុអ្វីបានជាធ្វើដូច្នេះ យើងខ្ញុំជាមនុស្សវិស័យដូចជាអ្នករាល់គ្នាដែរ..."។ សាវ័កប៉ុលមានប្រសាសន៍ដូចសាវ័កពេត្រុស ពេលដែលលោកកូនេលាសបានក្រាបថ្វាយបង្គំលោក។ លោកមិនព្រមអោយលោកកូនេលាសថ្វាយបង្គំលោកជាដាច់ខាត។

មនុស្សមិនគួរធ្វើជាអ្នកដែលអោយមនុស្សដូចគ្នាថ្វាយបង្គំឡើយ។ គ្រីស្ទបរិស័ទក៏ដូចគ្នាដែរ មិនត្រូវអោយមានអ្នកណាម្នាក់មកលុតជង្គង់ថ្វាយបង្គំខ្លួនទេ។ ប៉ុន្តែទោះបីព្រះជាម្ចាស់បង្គាប់ថា មិនអោយគ្រីស្ទបរិស័ទទទួលការថ្វាយបង្គំពីអ្នកណា គ្រីស្ទបរិស័ទខ្លះសព្វថ្ងៃ ចូលចិត្តអោយគេលើកជើងសរសើរដំកើងដល់ខ្លួនណាស់។ កិរិយាប្រព្រឹត្តបែបនេះ ខុសនឹងព្រះបន្ទូលឆ្ងាយដូចមេឃហើយនិងដី។

> **[១៧] ប៉ុន្តែ ទ្រង់មិនដែលលែងមានទីបន្ទាល់ ពីព្រះអង្គទ្រង់ទេ ដោយទ្រង់តែងតែផ្សាយព្រះគុណមក គឺទ្រង់ប្រោសប្រទានឱ្យភ្លៀងធ្លាក់ចុះពីលើមេឃ ឱ្យមានរដូវដ៏សំបូរ ដើម្បីនឹងបំពេញចិត្តយើងដោយអាហារ នឹងសេចក្តីអំណរ [១៨] តែដែលគាត់អធិប្បាយសេចក្តីទាំងនោះដល់គេ នោះឃាត់គេ មិនឱ្យថ្វាយយញ្ញបូជាដល់ខ្លួនសឹងតែមិនបានផង (កិច្ចការ១៤:១៧-១៨)។**

សាវ័កប៉ុលព្យាយាមបង្ហាត់បង្រៀន នឹងប្រាប់ដល់អ្នកលីស្ត្រាអោយបែរភ្នែកចេញពីលោក សំឡឹងទៅឯព្រះជាម្ចាស់ ដែលទ្រង់ជាអង្គនិម្មាបនិក គឺជាអង្គដែលបង្កបង្កើតផ្ទៃមេឃនិងផែនដី ព្រមទាំងរបស់អ្វីសព្វសារពើផង។ លោកចង់អោយអ្នកស្រុកទាំងនោះ កុំអោយចេះតែជឿថា អ្វីក៏ជាព្រះដែរនោះ គឺត្រូវអោយជឿថា ព្រះមានតែមួយអង្គគត់ ដែលសម្តែងមកអោយមនុស្សលោកស្គាល់តាមរយៈអង្គព្រះយេស៊ូវគ្រីស្ទ។

**មានពួកសាសន៍យូដាខ្លះ មកពីអាន់ទីយ៉ូក នឹងអ៊ីកូនាម គេបញ្ចុះបញ្ចូលហ្វូងមនុស្ស ឱ្យចោលប៉ុលនឹងថ្ម រួចគេអូសគាត់ចេញទៅក្រៅទុកចោល ដោយស្មានថា បានស្លាប់ហើយ (កិច្ចការ ១៤:១៩)។**

ពួកអ្នកស្រុកលីស្ត្រា ពិតជាមនុស្សក្រឡិចក្រឡុចមែន។ ម្សិលមិញគេនាំគ្នាលើកលោកប៉ុលនឹងលោកបាណាបាសថ្វាយបង្គំថាជាព្រះ។ លុះលោកបង្គាប់ប្រាប់គេថា លោកមិនមែនជាព្រះទេ គេនាំគ្នាគប់លោកប៉ុលនឹងដុំថ្ម រហូតដល់ស្លាប់ផង។

តើដំណើររឿងនេះ មិនមែនដូចជាមនុស្សលោកសព្វថ្ងៃទេឬ? មនុស្សលោកឧស្សាហ៍តាមគ្នាណាស់។ មួយថ្ងៃបើមានមនុស្សស្លៀកសំពត់ខ្លីច្រើន គេនាំគ្នាស្លៀកសំពត់ខ្លីរហូតទៅដល់ពិបាកមើល។ មួយថ្ងៃទៀត បើឃើញមានមនុស្សគេស្លៀកសំពត់

វែង គេនាំគ្នាកាត់សំពត់វែងស្ទើរអស់ពីផ្សារ។ គេនាំគ្នាស្លៀកតាមគ្នាយ៉ាងដូច្នោះ។ មនុស្សលោកពិតជាមានលក្ខណៈចេះតែតាមគ្នីតាមគ្នា មិនចេះរកហេតុផលខុសត្រូវខ្លួនឯងឡើយ។

អ្នកស្រុកលីស្ត្រា នាំគ្នាគប់សម្លាប់សាវ៉ែលប៉ុលដោយដុំថ្ម រួចហើយអូសលោកទៅចោលនៅខាងក្រៅទីក្រុង។ តើសាវ៉កប៉ុលស្លាប់មែនឬ? ខ្ញុំជឿថា សាវ៉កប៉ុលពិតជាស្លាប់មែន។ ក្រោយមកទៀត លោកបញ្ជាក់នៅក្នុងគម្ពីរ២កូរិនថូស១២:២-៤ អំពីហេតុការណ៍នោះថា "ខ្ញុំស្គាល់មនុស្សម្នាក់នៅក្នុងព្រះគ្រីស្ទ ដែលបានលើកឡើងទៅស្ថានសួគ៌នៅជាន់ទី៣ នោះប្រហែល១៤ឆ្នាំមកហើយ ទោះបើក្នុងរូបកាយ ឬក្រៅពីរូបកាយ នោះខ្ញុំមិនដឹងទេ មានតែព្រះដែលទ្រង់ជ្រាប។ ខ្ញុំស្គាល់មនុស្សនោះ (ទោះបើក្នុងរូបកាយ ឬក្រៅពីរូបកាយក្តី ខ្ញុំមិនដឹងទេ មានតែព្រះដែលទ្រង់ជ្រាប) ថា អ្នកនោះបានលើកឡើងទៅដល់ស្ថានបរមសុខ ហើយបានឮពាក្យដែលថ្លែងប្រាប់មិនបាន ក៏គ្មានច្បាប់ឱ្យមនុស្សណានិយាយឡើយ"។ តើមនុស្សដែលសាវ៉កប៉ុលនិយាយថា លោកស្គាល់នោះ គឺជានរណា? មនុស្សនោះ គឺជាសាវ៉កប៉ុលខ្លួនឯង។ លោកបញ្ជាក់បន្ថែមទៀត នៅក្នុង៧ថា "ហើយក្រែងខ្ញុំកើតមានចិត្តធំ ដោយព្រោះការបើកសំដែងហួសល្បត់នោះ បានជាមានបន្លា១ចាត់មកក្នុងសាច់ឈាមខ្ញុំ គឺជាទេវតារបស់អារក្សសាតាំង ដែលមកធ្វើទុក្ខខ្ញុំ ដើម្បីកុំឱ្យខ្ញុំមានចិត្តធំឡើយ (២កូរិនថូស១២:៧)។ ខ្ញុំជឿពិតប្រាកដថា ព្រះជាម្ចាស់បានប្រោសសាវ៉កប៉ុលអោយរស់ពីស្លាប់ឡើងវិញ។ បន្ទាប់ពីអ្នកស្រុកលីស្ត្រាគប់សម្លាប់លោកនឹងថ្ម។

ហេតុអ្វីបានជាព្រះដ៏មានគ្រប់ព្រះចេស្តា បណ្តោយអោយគេគប់សម្លាប់សាវ៉កប៉ុល? គម្ពីរកាឡាទី៦:៧ ឆ្លើយនឹងសំណួរនេះ "កុំឱ្យច្រឡំឡើយ នឹងបញ្ឆោតព្រះមិនបានទេ ដ្បិតពូជណាដែលមនុស្សព្រោះចុះ នោះនឹងច្រូតបានពូជនោះឯងវិញ"។ សាវ៉កប៉ុលច្រូតបានផលដែលលោកព្រោះពីមុន។ លោកគឺជាមនុស្សម្នាក់ដែលបង្គាប់អោយគេគប់សម្លាប់លោកស្ទេផាន។ ឥឡូវនេះ ផលដែលលោកបានធ្វើត្រឡប់មកជាន់កែងលោកវិញហើយ។ លោកព្រោះថ្ម ច្រូតបានថ្ម។ ច្បាប់របស់ធម្មជាតិមិនអាចផ្លាស់ប្រែបានទេ ដ្បិតព្រះជាម្ចាស់កំណត់ច្បាប់នោះ ដោយវិធីនោះឯង។ យើងព្រោះពូជអ្វី យើងច្រូតបានពូជនោះ។ ដាំដូង បេះបានដូង ដាំខ្នុរ បេះបានខ្នុរ ដាំចោរ បេះបានគុក ដាំទុក្ខបេះបានសោក។ សាវ៉កប៉ុលបង្គាប់អោយគេសម្លាប់លោកស្ទេផានដោយថ្ម ឥឡូវនេះ ថ្មដដែលនោះបានធ្លាក់មកលើរូបលោកវិញ។

**ប៉ុន្តែ ពួកសិស្សមកចោមព័ទ្ធគាត់ រួចគាត់ក្រោកឡើងចូលទៅក្នុងទីក្រុងវិញ ហើយដល់ថ្ងៃស្អែក គាត់នឹងបាណាបាសក៏ចេញទៅឯឌើបេ (កិច្ចការ១៤:២០)។**

ធ្វើដូចម្តេចដើម្បីអោយមនុស្សម្នាក់ដែលគេទើបនឹងសម្លាប់ដោយថ្ម អាចដើបដើរ ហើយធ្វើដំណើរបានយ៉ាងលឿនដូច្នេះ? ព្រះជាម្ចាស់ធ្វើការអស្ចារ្យយ៉ាងខ្លាំងចំពោះសាវ៉កប៉ុល។ លោកត្រូវគេគប់នឹងដុំថ្ម រហូតដល់ស្លាប់ ប៉ុន្តែលោកអាចដើបមក

វិញដើរបានទៅក្រុងមួយទៀត។ ការនេះមិនមែនអ្វី ក្រៅអំពីការដែលព្រះជាម្ចាស់ធ្វើការអស្ចារ្យនោះទេ។

> **[២១] ក្រោយដែលប្រកាសប្រាប់ដំណឹងល្អ ហើយបានសិស្សជាច្រើននៅក្រុងនោះ នោះក៏ត្រឡប់ទៅឯលីស្ត្រា អ៊ីកូនាម នឹងអាន់ទីយ៉ូកវិញ [២២] ព្រមទាំងចំរើនកំឡាំងដល់ពួកសិស្សឱ្យមានចិត្តរឹងប៉ឹងឡើង ហើយទូន្មានឱ្យនៅស្ថិតស្ថេរក្នុងសេចក្តីជំនឿ ដោយពាក្យថា ត្រូវតែទ្រាំរងទុក្ខវេទនាជាច្រើន ទើបនឹងចូលទៅក្នុងនគរព្រះបាន (កិច្ចការ១៤:២១-២២)។**

ទីក្រុងឌើបេ ជាចំណុចបកក្រោយនៃដំណើររបស់សាវ័កប៉ុល។ លោកទៅដល់ទីនោះ រួចហើយត្រឡប់សារដានមកកាន់ទីក្រុងលីស្ត្រា អ៊ីកូនាម ហើយនិងអាន់ទីយ៉ូកនៅក្នុងខេត្តពីស៊ីឌាវិញ។

> **កាលបានរើសពួកចាស់ទុំតាំងឡើងក្នុងគ្រប់ទាំងពួកជំនុំ ហើយអធិស្ឋានទាំងតម នោះក៏ប្រគល់គេទុកនឹងព្រះអម្ចាស់ ដែលគេបានជឿដល់ទ្រង់ហើយ (កិច្ចការ១៤:២៣)។**

លោកនាំគ្នាត្រឡប់មកខេត្តពីស៊ីឌា នឹងខេត្តប៉ាមភីលាវិញ រួចហើយលោកចាប់ផ្តើមបង្រៀនព្រះបន្ទូលរបស់ព្រះអង្គនៅក្នុងទីក្រុងពើកាទៀត។ បន្ទាប់ពីទីក្រុងពើកា លោកធ្វើដំណើរចុះទៅទីក្រុងអាតាលីយ៉ា រួចហើយចុះសំពៅត្រឡប់មកទីក្រុងអាន់ទីយ៉ូកនៅក្នុងខេត្តស៊ីរីវិញ។

> **២៦ ក៏ចុះសំពៅពីទីនោះ ត្រឡប់ទៅឯអាន់ទីយ៉ូកវិញ ជាកន្លែងដែល**
> **គេបានទុកដាក់អ្នកទាំង២ ក្នុងព្រះគុណនៃព្រះ សំរាប់ការដែល**
> **ទើបនឹងធ្វើសំរេច ២៧ លុះដល់ហើយ ក៏ប្រមូលពួកជំនុំមក ថ្លែង**
> **ប្រាប់ពីការដែលព្រះបានធ្វើដោយសារខ្លួន ហើយពីទ្រង់បានបើក**
> **ទ្វារនៃសេចក្តីជំនឿដល់សាសន៍ដទៃដែរ ២៨ រួចក៏នៅទីនោះជាមួយ**
> **នឹងពួកសិស្សជាយូរក្រែល (កិច្ចការ១៤:២៦-២៨)។**

សាវ័កប៉ុលនឹងលោកបាណាបាស នាំគ្នាធ្វើដំណើរមកដល់ទីក្រុងអាន់ទីយ៉ូកដែលជាក្រុមជំនុំបញ្ជូនលោកអោយទៅធ្វើការបម្រើព្រះអង្គ។ លោកមកដល់ទីនោះ ក៏រាយការណ៍ជូនក្រុមជំនុំអំពីកិច្ចការ ដែលលោកទាំងនោះបានបញ្ជូនលោកទៅអោយផ្សាយដំណឹងល្អ។ សេចក្តីដែលយើងឃើញនៅក្នុងជំពូក១៤ បញ្ជាក់យ៉ាងច្បាស់ថា ព្រះជាម្ចាស់បើកទ្វារសម្រាប់អោយដំណឹងល្អបានរីកសាយទៅដល់សាសន៍ដទៃ។ កាលពីប៉ុន្មានឆ្នាំមុន ដំណឹងល្អបានរីកសុះសាយនៅក្នុងចំណោមពួកសាសន៍យូដា។ ឥឡូវនេះ

មានសាសន៍ដទៃផង សាសន៍យូដាផង ជាអ្នកជឿដល់ព្រះអម្ចាស់យេស៊ូវ។ ក្រុមជំនុំភាគច្រើន នៅអាស៊ីចុងខាងលិច សុទ្ធតែពួកសាសន៍ដទៃ។ ដំបូងឡើយ សាវ័កប៉ុលនាំដំណឹងល្អទៅដល់សាលាប្រជុំរបស់សាសន៍យូដា តែដោយសារសាសន៍យូដានាំគ្នាបដិសេធដំណឹងល្អរបស់ព្រះអម្ចាស់យេស៊ូវ សាវ័កប៉ុលក៏នាំដំណឹងល្អទៅអោយសាសន៍ដទៃស្តាប់វិញ។

យើងស្លេះការសិក្សាគម្ពីរកិច្ចការត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តមដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"